## សកម្មភាពសំខាន់ៗ

### លទ្ធផលទី ១៖

- បង្កើតថ្នាក់បំប៉ន ដើម្បីធានាថាពួកគេមានសមត្ថភាពគ្រប់គ្រាន់លើបំណិនអំណាន និងបំណិននព្វន្ត និងអាចឆ្លងភូមិសិក្សាទៅអនុវិទ្យាល័យបាន
- បង្កើតប្រព័ន្ធរំលឹកជាមុននៅតាមសាលារៀនគោលដៅ ដើម្បីទប់ស្កាត់ការបោះបង់ការសិក្សារបស់សិស្ស
- បង្កើតប្រព័ន្ធទិន្នន័យតាមដានកុមារ និងយុវជនងាយរងគ្រោះ
- ផ្សារភ្ជាប់កម្មវិធីអប់រំបំណិនជីវិតជាមួយនឹងការផ្តល់កញ្ចប់ថវិកាដល់អាណាព្យាបាលសិស្សអាហារូបករណ៍ ដើម្បីបង្កើនប្រាក់ចំណូល
- ផ្តល់អាហារូបករណ៍ដល់សិស្សងាយរងគ្រោះនៅកម្រិតអនុវិទ្យាល័យ
- បណ្តុះបណ្តាលកម្មវិធីបំណិនជីវិតក្នុងសាលារៀន ដោយប្រើសៀវភៅបំណិនជីវិតរបស់ក្រសួងអប់រំ យុវជន និងកីឡាដែលមានជាង៣០ប្រធានបទ  រួមមាន៖ បំណិនជីវិតផ្នែកសង្គម សេដ្ឋកិច្ច និងត្រៀមចូលវិជ្ជាជីវៈ។
- ជម្រុញឱ្យមានការប្រើប្រាស់កម្មវិធីប្រឹក្សាអាជីពតាមរយៈសារអេឡិចត្រូនិច (ត្រីវិស័យ App)។

### លទ្ធផលទី ២៖

- បង្កើតប្រព័ន្ធបណ្តាញវ៉ៃឆ្លាតជាមួយនឹងឱកាសការងារ
- បង្កើតមណ្ឌលប្រឹក្សាយោបល់សាកល្បងចំនួនបីកន្លែង
- បំប៉នសមត្ថភាពអង្គការ-សង្គមស៊ីវិល ដើម្បីពង្រឹងតួនាទីស្នូលរបស់ពួកគេ ក្នុងការយល់ដឹងអំពីតម្រូវការរបស់កុមារនិងយុវជន និងបញ្ជូនពួកគេ ឱ្យទទួលបានការងារ និងការបណ្តុះបណ្តាលវិជ្ជាជីវៈ
- បង្កើតក្រុមយុវជនស្រាវជ្រាវផ្នែកក្នុងតាមបែបការចូលរួម
- ផ្តល់កញ្ចប់ថវិកាដល់អង្គការសង្គមស៊ីវិល និងស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីធ្វើឱ្យប្រសើរឡើងនូវសេវាបណ្តុះបណ្តាលវិជ្ជាជីវៈ និងការតម្រង់ទិសអាជីពដល់យុវជន
- បង្កើតឱកាសការងារដល់យុវជន។

### លទ្ធផលទី ៣៖

- បង្កើតក្រុមមិត្តជួយមិត្តនៅក្នុងមណ្ឌលប្រឹក្សាយោបល់
- ធ្វើយុទ្ធនាការស្តីពីសិទ្ធិសេដ្ឋកិច្ចសង្គមរបស់យុវជន និងកុមារីតាមរយៈប្រព័ន្ធផ្សព្វផ្សាយចម្រុះ និងការចូលរួមរបស់ដៃគូ។

## ព័ត៌មានលម្អិតរបស់គម្រោង

**រយៈពេល៖** ០៣ឆ្នាំ (ថ្ងៃទី០១ ខែមករា ឆ្នាំ២០២០ ដល់ថ្ងៃទី៣១  ខែធ្នូ ឆ្នាំ២០២២)

**ទីតាំង៖** ខេត្តចំនួន០៣ (កំពង់ចាម ត្បូងឃ្មុំ និងកំពង់ឆ្នាំង)




## អាសយដ្ឋាន៖

| | |
|---|---|
| ការិយាល័យ: | សាលាគរុកោសល្យ និងវិក្រឹតការខេត្ត ផ្លូវជាតិលេខ ៧ ចាស់ ក្រុងកំពង់ចាម ខេត្តកំពង់ចាម |
| ប្រអប់សំបុត្រ: | P.O Box ១៦២១ ភ្នំពេញកម្ពុជា |
| លេខទូរសព្ទ: | ០៤២-៩៤១-៤៨១ / ០៤២-៩៤១-៩១៨ |
| អ៊ីមែល: | kape@kapekh.org |
| ហ្វេសប៊ុក: | Facebook.com/kapeaction |

| | |
|---|---|
| KAPE | www.kapekh.org |
| WeWorld-GVC | www.weworld-gvc.it |
| YCC | www.ycc.org.kh |
| BSDA | www.bsda-cambodia.org |

កម្មវិធីនេះអនុវត្តដោយអង្គការ សកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (KAPE) អង្គការ We-World-GVC អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) និងអង្គការ ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)។ ទស្សនៈនៅក្នុងព្រឹត្តិបត្រនេះមិនប៉ះពាល់ទៅនឹងទស្សនៈរបស់សហភាពអឺរ៉ុបទេ។

# SEEK

## គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា



This project is co-funded by the European Union

# សេចក្តីសង្ខេប

នៅប្រទេសកម្ពុជា កម្រិតភាពក្រីក្របានធ្លាក់ចុះនៅកំឡុងជាង ១០ឆ្នាំចុងក្រោយនេះ ហើយកំណើនសេដ្ឋកិច្ចមានការកើនឡើងជាមធ្យមប្រមាណ ៧% ជារៀងរាល់ឆ្នាំ។ ទោះជាយ៉ាងនេះក្តី ប្រជាជនប្រហែលជា៧១% រស់នៅក្រោមប្រាក់ចំណូល៣ដុល្លារក្នុងមួយថ្ងៃ។ អ្វីដែលគួរឱ្យភ្ញាក់ផ្អើល អត្រាយុវជនដែលគ្មានការងារធ្វើ មានត្រឹមតែ ៣%ប៉ុណ្ណោះ ប៉ុន្តែយុវជនភាគច្រើនប្រកបការងារដោយគ្មានជំនាញជាក់លាក់ និងទទួលបានប្រាក់កម្រៃទាប។ ប្រព័ន្ធគ្រប់គ្រងព័ត៌មានការអប់រំឆ្នាំ២០១៨ បានបង្ហាញពីរបាយការណ៍អត្រាបោះបង់ការសិក្សានៅកម្រិតអនុវិទ្យាល័យមានប្រមាណ ១៧%-១៩% នៅក្នុងប្រទេសកម្ពុជា។

សិស្សបញ្ចប់ការសិក្សាកម្រិតមូលដ្ឋាន ទទួលបានចំណេះដឹងផ្នែកអប់រំបំណិនជីវិត និងប្រឹក្សាអាជីពនៅតាមសាលារៀននៅមានកម្រិតទាបដែលនាំឱ្យយុវជនខ្វះបំណិន និងបទពិសោធន៍កាន់តែខ្លាំងឡើង។

គម្រោងលើកកម្ពស់ការអប់រំ និងការងារនៅកម្ពុជា (SEEK) បង្កើតឡើងក្នុងគោលបំណង ដើម្បីបំពេញនូវសិទ្ធិសេដ្ឋកិច្ច និងសង្គមរបស់យុវជន ជាពិសេសការយកចិត្តទុកដាក់ទៅលើស្រ្តីមកពីសហគមន៍ជនជាតិខ្មែរឥស្លាម តាមរយៈទទួលបានការអប់រំប្រកបដោយគុណភាព និងបរិយាប័ន្ន ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងការងារដែលសមរម្យ។

គម្រោងនេះគាំទ្រដោយសហភាពអឺរ៉ុប (EU) អនុវត្តដោយអង្គការសកម្មភាពសម្រាប់ការអប់រំនៅកម្ពុជា (ខេប/KAPE) អង្គការ WeWord-GVC អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម (BSDA) និងអង្គការ ក្រុមប្រឹក្សាយុវជនកម្ពុជា (YCC)។






# គោលបំណង

- កុមារ និងយុវជនទទួលបានការអប់រំប្រកបដោយបរិយាប័ន្នដែលជាមធ្យោបាយមួយក្នុងការលើកកម្ពស់លទ្ធភាពការងាររបស់ពួកគេ ជាពិសេសក្មេងស្រីដែលមកពីសហគមន៍ជនជាតិចាម។
- សង្គមស៊ីវិល ចូលរួម និងមានសិទ្ធិអំណាចក្នុងការស្វែងរកដំណោះស្រាយនៅក្នុងសហគមន៍ដល់យុវជនងាយរងគ្រោះទៅលើផ្នែកសេដ្ឋកិច្ច និងសង្គមដើម្បីទទួលបានការបណ្តុះបណ្តាលវិជ្ជាជីវៈ តម្រង់ទិសអាជីព និងឱកាសការងារ។
- បង្កើនបណ្តាញយុវជន និងសមត្ថភាពតស៊ូមតិ។




# គោលដៅ និងអ្នកទទួលផល

**65**
នាយកសាលា

**340**
គ្រូបង្រៀន

**15,250**
យុវជនក្នុងសាលា
(៣០% ជនជាតិចាម)

**1,000**
យុវជនក្រៅសាលា
(១៥% ជនជាតិចាម)

**12**
អង្គការសង្គមស៊ីវិល

**20**
ក្រុមជួយខ្លួនឯង

**6**
ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ

**50**
ក្លិបកុមារ និងយុវជន

**30,500**
សហគមន៍ និងអាណាព្យាបាលសិស្ស

**500,000**
អ្នកទទួលផលតាមរយៈយុទ្ធនាការរបស់យុវជន

**50**
សាលាបឋមសិក្សា

**15**
អនុវិទ្យាល័យ